

# ការធ្វើបន្ទាល់ផ្ទាល់ខ្លួន

## 11. SHARING YOUR TESTIMONY

Copyright © 2004, 2018 Barnabas Mam



វត្ថុបំណង

រៀនឲ្យដឹងថា

តើការធ្វើជាបន្ទាល់អំពីព្រះគ្រិស្តមានសារៈសំខាន់យ៉ាងណា

តើលោកប៉ូលយកបទពិសោធន៍ផ្ទាល់ខ្លួនមកធ្វើបន្ទាល់អំពីព្រះគ្រិស្តដោយរបៀបណា

ដើម្បីឲ្យអ្នកមានឱកាសអាចនាំញាតិមិត្តរបស់អ្នកមកទទួលជឿព្រះគ្រិស្ត

តាមរយៈការធ្វើបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នក។

## ១.ឱកាសសម្រាប់ធ្វើបន្ទាល់ផ្ទាល់ខ្លួន

1. AN OPPORTUNITY TO SHARE YOUR TESTIMONY

យ៉ូហាន ៤:៣៥

៣៥ អ្នករាល់គ្នាតែងពោលថា"បួនខែទៀតដល់រដូវចំរូត"។
រីឯខ្ញុំវិញ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថាចូរមើលទៅវាលស្រែមើល៍ ស្រូវទុំល្អមច្រូតហើយ។



រដូវចម្រូត THE HARVEST
គឺជាឱកាសដ៏សមស្របមួយ(an appropriate opportunity )
ឬស្ថានភាពដ៏មានអំណោយផលមួយ(a favorable situation) ដែលអ្នកអាចនាំ
សាច់ញាតិ(relative) មិត្តរួមស្រុក(fellow country folk) មិត្តរួមថ្នាក់(classmate)
មិត្តរួមសាលា(schoolmate) ឬមិត្តរួមអាជីព(fellow worker)ណាម្នាក់របស់អ្នក
ឲ្យមកទទួលជឿព្រះគ្រិស្តតាមរយៈការធ្វើបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នក( your testimony ) ។
អ្នកអាចឆក់ឱកាស(seize an opportunity)ក្នុងពេលដែលអ្នកណាម្នាក់មានវិបត្តិ
ដូចជាវិបត្តិផ្លូវចិត្ត( emotional crisis ) វិបត្តិអាពាហ៍ពិពាហ៍( marital crisis )
វិបត្តិហិរញ្ញវត្ថុ( financial crisis ) មានជំងឺ( sickness )
ឬមានវិបត្តិអ្វីផ្សេងទៀត( any other crisis )
ទៅលើកទឹកចិត្តគាត់ដោយការធ្វើបន្ទាល់( to encourage him with a testimony ) ។
វិបត្តិមួយគឺជាឱកាសមួយ !( A crisis is an opportunity! )

២.ព្រះយេស៊ូត្រូវការបន្ទាល់ច្រើននាក់ទៀត

2. JESUS NEEDS MORE WITNESSES

លូកា ១០:១-២

១ ក្រោយមក ព្រះអម្ចាស់ជ្រើសយកសិស្សចិតសិបពីររូបទៀត
ហើយចាត់គេពីរៗនាក់ឲ្យទៅតាមភូមិ
តាមស្រុកនានាដែលព្រះអង្គបម្រុងនឹងយាងទៅ។
២ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖
«ស្រូវដែលត្រូវច្រូតមានច្រើនណាស់ តែអ្នកច្រូតមានតិចពេក។
ហេតុនេះ ចូរអង្វរម្ចាស់ស្រែឲ្យចាត់ អ្នកច្រូត មកក្នុងស្រែរបស់លោក។



អង្វរម្ចាស់ស្រែឲ្យចាត់អ្នកច្រូតមកក្នុងស្រែរបស់លោក
គឺអធិស្ឋានសូមឲ្យព្រះជាម្ចាស់ចាត់បន្ទាល់( សាក្សី witness មរណសាក្សី martyr ម៉ារទូស )
ឲ្យមកធ្វើបន្ទាល់អំពីព្រះគ្រីស្ត( to witness Christ )នៅតាមផ្ទះ( home ) សាលា( school )
ស្ថាប័ន( institution ) អង្គការ( organization ) ក្រុមហ៊ុន( company )
ក្រសួង( ministry ) និងសហគមន៍( community )ណាមួយលើពិភពលោក។

៣.បន្ទាល់របស់ព្រះគ្រិស្ដ

3. THE WITNESSES OF CHRIST

កិច្ចការ ១:៨

៨ ប៉ុន្តែ អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ
គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា។
អ្នករាល់គ្នានឹងធ្វើជា បន្ទាល់របស់ខ្ញុំ
នៅក្នុងក្រុងយេរូសាឡឹម
ក្នុងស្រុកយូដាទាំងមូល
ក្នុងស្រុកសាម៉ារី
និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី»។



បន្ទាល់( សាក្សី មរណសាក្សី )របស់ព្រះគ្រិស្តទទួលឫទ្ធានុភាពនៃព្រះវិញ្ញាណ
ដើម្បីធ្វើបន្ទាល់( ផ្តល់សក្ខីភាព )អំពីព្រះគ្រិស្តនៅលើពិភពលោកនេះ
ដោយផ្តើមចេញពីភូមិរបស់គាត់( យេរូសាឡឹម )
ខេត្តរបស់គាត់( ស្រុកយូដា ) កុលសម្ព័ន្ធជិតខាងគាត់( ស្រុកសាម៉ារី )
និងប្រទេសផ្សេងៗទៀតលើពិភពលោក( ស្រុកដាច់ស្រយាលនៃផែនដី )។

បន្ទាល់(មរណសាក្សី)របស់ព្រះគ្រិស្ត
A WITNESS (MARTYR) OF CHRIST
គឺមនុស្សដែលជឿព្រះគ្រិស្ត(A person who believes in Christ)
រួមរស់ជាមួយព្រះគ្រិស្ត(has a fellowship with Christ)
ឃើញសិរីរុងរឿងរបស់ព្រះគ្រិស្ត(sees the glory of Christ)
ឮព្រះបន្ទូលរបស់ព្រះគ្រិស្ត(hears the words of Christ)
និងប្តូរផ្តាច់ធ្វើបន្ទាល់អំពីហេតុការណ៍ដែលគាត់ដឹងអំពីព្រះគ្រិស្ត
(is committed to witness what he knows about Christ)
ប្រាប់អ្នកជិតខាងគាត់និងអ្នកស្រុកឆ្ងាយដោយពឹងលើឫទ្ធានុភាពរបស់ព្រះវិញ្ញាណ។
(to those who are near him or far from him by the power of the Holy Spirit.)

ក.លោកភីលីពជាបន្ទាល់ជើងថ្មី
A. PHILIP, THE JUNIOR WITNESS
យ៉ូហាន ១:៤៣-៤៧
៤៣ លុះថ្ងៃបន្ទាប់មកទៀត
ព្រះយេស៊ូសព្វព្រះហឫទ័យយាងទៅស្រុកកាលីឡេ។
ព្រះអង្គបានជួបលោកភីលីព ហើយមានព្រះបន្ទូលទៅគាត់ថា៖
«សូមអញ្ជើញមកតាមខ្ញុំ»។ ៤៤ លោកភីលីពជាអ្នកភូមិបេតសៃដា
ដូចលោកអនទ្រេនិងលោកពេត្រុសដែរ។
៤៥ លោកភីលីពទៅជួបលោកណាថាណែល ប្រាប់គាត់ថា៖
«ព្រះអង្គដែលលោកម៉ូសេបានចារទុកក្នុងគម្ពីរវិន័យ
ហើយគម្ពីរព្យាការីក៏មានចែងទុកដែរនោះ
ឥឡូវនេះយើងបានជួបហើយ ព្រះអង្គមាននាមថា យេស៊ូ
ជាអ្នកភូមិណាសារ៉ែតជាបុត្ររបស់លោកយ៉ូសែប»។

៤៦ លោកណាថាណែលពោលតបទៅលោកភីលីពវិញថា៖
«ពុំដែលមានអ្វីល្អអាចចេញពីភូមិណាសារ៉ែតបានឡើយ»។
៤៧ លោកភីលីពប្រាប់គាត់ថា៖«សូមអញ្ជើញមក អ្នកនឹងបានឃើញ!»។
កាលព្រះយេស៊ូទតឃើញលោកណាថាណែលដើរមករកព្រះអង្គ
ព្រះអង្គមានព្រះបន្ទូលអំពីគាត់ថា៖
«អ្នកនេះជាជាតិអ៊ីស្រាអែលដ៏ពិតប្រាកដមែនដ្បិតគាត់គ្មានពុតត្បុតអ្វីក្នុងខ្លួនសោះ»។

លោកភីលីពជាបន្ទាល់ជើងថ្មី( junior witness )
ឬសាក្សីដែលគ្មានបទពិសោធន៍( unexperienced witness )មួយរូបរបស់ព្រះគ្រិស្ត។
លោកធ្វើបន្ទាល់( ផ្តល់សក្ខីភាព )អំពីព្រះគ្រិស្តតាមបែបអ្នកជឿថ្មី
គឺគាត់ស្គាល់ព្រះគ្រិស្តបានប៉ុណ្ណា គាត់ធ្វើបន្ទាល់ពីព្រះអង្គបានប៉ុណ្ណឹង។
ពេលណាថាណែលជាមិត្តរបស់គាត់បដិសេធមិនព្រមទទួលស្គាល់ព្រះគ្រិស្ត
គាត់បបួលណាថាណែលឲ្យទៅជួបព្រះគ្រិស្តដោយផ្ទាល់តែម្តង។

ខ.លោកយ៉ូហានជាបន្ទាល់ជើងចាស់
B. JOHN, THE SENIOR WITNESS
យ៉ូហាន ១៩:៣២-៣៧
៣២ ពួកទាហាននាំគ្នាមកវាយបំបាក់ជើងអ្នកទោសទីមួយ
និងអ្នកទោសទីពីរដែលជាប់លើឈើឆ្កាងជាមួយព្រះអង្គ។
៣៣ លុះមកដល់ព្រះយេស៊ូ
គេឃើញព្រះអង្គសោយទិវង្គតផុតទៅហើយ
គេមិនបំបាក់ព្រះបាទាព្រះអង្គទេ
៣៤ ប៉ុន្តែ ទាហានម្នាក់យកលំពែងចាក់ត្រង់ចន្លោះឆ្អឹងជំនីរព្រះអង្គ
ស្រាប់តែមានទឹកនិងលោហិតហូរចេញមកមួយរំពេច។
៣៥ សិស្សម្នាក់ដែលបានឃើញ ធ្វើជា បន្ទាល់ អំពីហេតុការណ៍នេះ
ហើយសក្ខីភាពរបស់គាត់ពិតប្រាកដមែន។
ព្រះអង្គដឹងថាសិស្សនោះនិយាយសេចក្តីពិតដើម្បីឲ្យអ្នករាល់គ្នាជឿដែរ។

៣៦ ហេតុការណ៍នេះកើតឡើង
ស្របតាមសេចក្ដីដែលមានចែងទុកក្នុងគម្ពីរមកថា៖
«គ្មានឆ្អឹងណាមួយរបស់លោកត្រូវបាក់បែកឡើយ»។
៣៧ មានអត្ថបទគម្ពីរមួយទៀតចែងថា៖
«គេនាំគ្នាមើលអ្នកដែលគេចាក់ទម្លុះ»។

លោកយ៉ូហានជាបន្ទាល់ដើងចាស់( senior witness )
ឬសាក្សីដែលមានបទពិសោធន៍( experienced witness )មួយរូបរបស់ព្រះគ្រិស្ត។
លោកធ្វើបន្ទាល់( ផ្តល់សក្ខីភាព )អំពីព្រះគ្រិស្តតាមបែបអ្នកជឿចាស់
គឺគាត់ស្គាល់ព្រះគ្រិស្តយ៉ាងច្បាស់ហើយធ្វើបន្ទាល់ពីព្រះអង្គយ៉ាងច្បាស់ដែរ។
លោកធ្វើបន្ទាល់អំពីអ្វីៗដែលលោកបានឃើញព្រះគ្រិស្តធ្វើដោយផ្ទាល់
អំពីអ្វីៗដែលលោកបានឮព្រះគ្រិស្តមានបន្ទូលដោយផ្ទាល់
និងអំពីអ្វីៗដែលលោកបានពិសោធន៍ដោយផ្ទាល់ក្នុងការរស់នៅរួមជាមួយព្រះគ្រិស្ត។

៤.ភាពសំខាន់នៃការធ្វើបន្ទាល់
4. THE IMPORTANCE OF A TESTIMONY
ក.ការធ្វើបន្ទាល់នាំមនុស្សជាច្រើនឲ្យមកទទួលជឿព្រះគ្រិស្ត
A. IT LEADS MANY PEOPLE TO ACCEPT CHRIST
យ៉ូហាន ៤:៣៩
៣៩ ក្នុងភូមិនោះ មានអ្នកស្រុកសាម៉ារីជាច្រើន បានជឿ លើព្រះយេស៊ូ
ដោយសារពាក្យដែលស្ត្រីនោះបានបញ្ជាក់ប្រាប់ថា
"លោកមានប្រសាសន៍ប្រាប់ខ្ញុំនូវអំពើទាំងប៉ុន្មានដែលខ្ញុំបានប្រព្រឹត្ត"។



ការធ្វើបន្ទាល់អំពីហេតុការណ៍ដែលអ្នកដឹងឮអំពីព្រះគ្រិស្ត
ជាពិសេសអំពីកិច្ចការដ៏ល្អអស្ចារ្យដែលព្រះអង្គបានធ្វើចំពោះអ្នកផ្ទាល់
អាចនាំឲ្យអ្នកជិតខាងអ្នកនិងអ្នកស្រុកឆ្ងាយមានឱកាសទទួលជឿព្រះគ្រិស្តដូចអ្នកដែរ។

ខ.ការធ្វើបន្ទាល់នាំឲ្យដំណឹងល្អរីកសាយភាយពាសពេញសកលលោកទាំងមូល
B. IT ACCELERATES THE SPREAD OF THE GOSPEL WORLDWIDE
ម៉ាថាយ ២៤:១៤
១៤ គេនឹងប្រកាសដំណឹងល្អអំពីព្រះរាជ្យនេះ
ពាសពេញ សកលលោកទាំងមូល
ទុកជាសក្ខីភាពដល់ជាតិសាសន៍ទាំងអស់។
ពេលនោះ ទើបដល់អវសានកាលនៃពិភពលោក។



ការធ្វើបន្ទាល់អំពីកិច្ចការដ៏ល្អអស្ចារ្យដែលព្រះគ្រិស្តបានធ្វើចំពោះអ្នកផ្ទាល់
អាចនាំឲ្យដំណឹងល្អរីកសាយភាយពាសពេញសកលលោកទាំងមូលយ៉ាងឆាប់រហ័ស
ហើយមនុស្សគ្រប់ជាតិសាសន៍នឹងមានឱកាសបានឮនិងជឿលើដំណឹងល្អរបស់ព្រះគ្រិស្ត។

គ.ការធ្វើបន្ទាល់នាំឲ្យអវសានកាលនៃពិភពលោកឆាប់មកដល់
C. IT SPEEDS UP THE COMING OF THE END TIME
ម៉ាថាយ ២៤:១៤
១៤ គេនឹងប្រកាសដំណឹងល្អអំពីព្រះរាជ្យ
នេះពាសពេញសកលលោកទាំងមូល
ទុកជាសក្ខីភាពដល់ជាតិសាសន៍ទាំងអស់។
ពេលនោះ ទើបដល់ អវសានកាលនៃពិភពលោក។



ការធ្វើបន្ទាល់អំពីកិច្ចការដ៏ល្អអស្ចារ្យដែលព្រះគ្រិស្តបានធ្វើចំពោះអ្នកផ្ទាល់
អាចនាំឲ្យដំណឹងល្អរីកសាយភាយពាសពេញសកលលោកទាំងមូលយ៉ាងឆាប់រហ័ស
ព្រះគ្រិស្តនឹងឆាប់យាងមកវិញ ហើយអវសានកាលនៃពិភពលោកនឹងឆាប់មកដល់។

ឃ.ការធ្វើបន្ទាល់ជួយអ្នកឲ្យមានជ័យជម្នះលើមារកំណាច
D. IT HELPS YOU TO OVERCOME THE DEVIL
វិវរណៈ ១២:១១
[១១] បងប្អូនយើងបានឈ្នះវា
ដោយសារព្រះលោហិតរបស់កូនចៀម
និងដោយ <u>សក្ខីភាពរបស់ពួកគេ</u>
ហើយបងប្អូនទាំងនោះបានស៊ូប្ដូរជីវិតឥតស្ដាយសោះឡើយ។



ការធ្វើបន្ទាល់អំពីកិច្ចការដ៏ល្អអស្ចារ្យដែលព្រះគ្រិស្តបានធ្វើចំពោះអ្នកផ្ទាល់
អាចនាំឲ្យអ្នករស់នៅប្រកបដោយជ័យជម្នះលើមារកំណាច
មិនថាវាប្រើកលល្បិចនិងយុទ្ធវិធីបែបណាដើម្បីវាយផ្ដួលអ្នកក៏ដោយ។

៥.ទីបន្ទាល់គំរូ 5. A TYPICAL TESTIMONY

ទីបន្ទាល់របស់សាវ័កប៉ូលជាទីបន្ទាល់គំរូមួយដែលមានលក្ខណៈពេញលេញ។
ទីបន្ទាល់គំរូរបស់ប៉ូលរាប់បញ្ចូលដំណាក់កាលទាំងបួននៃជីវិតដូចខាងក្រោម៖

កិច្ចការ ២២:៣-៥
ជីវិតចាស់របស់ប៉ូលមុនពេលទទួលជឿព្រះគ្រិស្ត

កិច្ចការ ២២:៦-៨
កម្លាំងដ៏ខ្លាំងក្លាដែលជំរុញប៉ូលឲ្យទទួលជឿព្រះគ្រិស្ត

កិច្ចការ ២២:៩-១៣
ព្រឹត្តិការណ៍ ពេលវេលា និងទីកន្លែងដែលប៉ូលទទួលជឿព្រះគ្រិស្ត

កិច្ចការ ២២:១៤-២១
ជីវិតថ្មី(ការផ្លាស់ប្រែ)របស់ប៉ូលក្រោយពេលទទួលជឿព្រះគ្រិស្ត។

ក.ជីវិតចាស់របស់ប៉ូលមុនពេលទទួលជឿព្រះគ្រិស្ត
A. PAUL’S OLD LIFE BEFORE HIS CONVERSION
កិច្ចការ ២២:៣-៥
ខ្ញុំឈ្មោះប៉ូលដែលមានឈ្មោះដើមថាសូល។ ខ្ញុំជាជនជាតិយូដា។ ខ្ញុំកើតនៅក្រុងតើសុសក្នុងស្រុកគីលីគា។ ប៉ុន្តែ ខ្ញុំបានមករស់នៅក្រុងយេរូសាឡឹមនេះតាំងពីកុមារ ហើយខ្ញុំបានទទួលការអប់រំតាមក្រឹត្យវិន័យនៃបុព្វបុរសរបស់យើងយ៉ាងតឹងរ៉ឹងពីសំណាក់លោកកាម៉ាលាល។ ខ្ញុំបានខ្នះខ្នែងបម្រើព្រះជាម្ចាស់ដូចបងប្អូនទាំងអស់គ្នានៅថ្ងៃនេះដែរ។ ខ្ញុំធ្លាប់បៀតបៀនអស់អ្នកដែលដើរតាមមាគ៌ារបស់ព្រះអម្ចាស់ រហូតដល់សម្លាប់គេ ហើយចាប់ចងមនុស្សប្រុសស្រីយកទៅឃុំឃាំងទៀតផង ដូចមានលោកមហាបូជាចារ្យនិងក្រុមព្រឹទ្ធាចារ្យជាសាក្សីស្រាប់។ ខ្ញុំបានទទួលលិខិតពីលោកទាំងនោះយកទៅជូនបងប្អូននៅក្រុងដាម៉ាស ដ្បិតខ្ញុំទៅទីនោះដើម្បីចាប់ចងពួកអ្នកដែលដើរតាមមាគ៌ានេះយកមកធ្វើទោសនៅក្រុងយេរូសាឡឹម។

ខ.កម្លាំងដ៏ខ្លាំងក្លាដែលជំរុញប៉ូលឲ្យទទួលជឿព្រះគ្រិស្ត
B. THE MIGHTY FORCE THAT PUSHED PAUL’S CONVERSION
កិច្ចការ ២២:៦-៨
ពេលខ្ញុំកំពុងតែធ្វើដំណើរទៅជិតដល់ក្រុងដាម៉ាសប្រមាណជាថ្ងៃត្រង់ស្រាប់តែមានពន្លឺមួយដ៏ភ្លឺត្រចះត្រចង់ចាំងពីផ្ទៃមេឃមកជុំវិញខ្ញុំ។ ខ្ញុំក៏ដួល ហើយឮសំឡេងមួយពោលមកខ្ញុំថា “សូលអើយ សូល! ហេតុដូចម្ដេចបានជាអ្នកបៀតបៀនខ្ញុំដូច្នេះ?”។ ខ្ញុំបានសួរវិញថា “លោកម្ចាស់អើយ តើលោកជានរណា?”។ សំឡេងនោះឆ្លើយមកខ្ញុំថា “ខ្ញុំជាយេស៊ូ អ្នកស្រុកណាសារ៉ែតដែលអ្នកកំពុងតែបៀតបៀន”។

គ.ព្រឹត្តិការណ៍ ពេលវេលា និងទីកន្លែងដែលប៉ូលទទួលជឿព្រះគ្រិស្ត

C. THE EVENT, TIME AND PLACE OF PAUL’S CONVERSION

កិច្ចការ ២២:៩-១៣

រីឯអស់អ្នកដែលធ្វើដំណើរជាមួយខ្ញុំក៏បានឃើញពន្លឺនោះដែរ តែមិនបានឮព្រះសូរសៀងទេ។ ខ្ញុំក៏សួរថា “ព្រះអម្ចាស់អើយ តើទូលបង្គំត្រូវធ្វើដូចម្ដេច ?”។ ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា “ចូរក្រោកឡើង ទៅក្រុងដាម៉ាសទៅ នៅទីនោះ គេនឹងប្រាប់អ្នកអំពីកិច្ចការទាំងប៉ុន្មានដែលព្រះជាម្ចាស់បង្គាប់ឲ្យអ្នកធ្វើ”។ ដោយខ្ញុំពុំអាចមើលអ្វីឃើញ ព្រោះតែពន្លឺរស្មីដ៏រុងរឿងនោះ អស់អ្នកដែលនៅជាមួយខ្ញុំបានដឹកដៃនាំខ្ញុំទៅក្រុងដាម៉ាស។ នៅក្រុងនោះមានបុរសម្នាក់ឈ្មោះអណាណាសជាអ្នកគោរពប្រណិប័តន៍ព្រះជាម្ចាស់ស្របតាមក្រឹត្យវិន័យ ហើយជនជាតិយូដានៅក្រុងដាម៉ាសគោរពរាប់អានគាត់គ្រប់ៗគ្នា។ គាត់មកឈរជិតខ្ញុំហើយពោលថា “បងសូលអើយ សូមឲ្យបងមើលឃើញវិញចុះ!”។ រំពេចនោះ ភ្នែកខ្ញុំក៏ភ្លឺឡើង ហើយខ្ញុំមើលឃើញគាត់។

ឃ.ជីវិតថ្មីរបស់ប៉ូលក្រោយពេលទទួលជឿព្រះគ្រិស្ត

D. PAUL’S NEW LIFE AFTER HIS CONVERSION

កិច្ចការ ២២:១៤-២១

គាត់មានប្រសាសន៍ថា “ព្រះនៃបុព្វបុរសរបស់យើងបានជ្រើសរើសបងដើម្បីឲ្យបងស្គាល់ព្រះហឫទ័យរបស់ព្រះអង្គ ឲ្យបងបានឃើញព្រះដ៏សុចរិត និងឲ្យបងបានឮព្រះបន្ទូលរបស់ព្រះអង្គផ្ទាល់តែម្ដង ដ្បិតបងនឹងធ្វើជាបន្ទាល់របស់ព្រះអង្គនៅមុខមនុស្សទាំងអស់ អំពីហេតុការណ៍ដែលបងបានឃើញ និងអំពីសេចក្ដីដែលបងបានឮ។ ដូច្នេះតើបងនៅបង្អែបង្អង់ដល់កាលណាទៀត សូមក្រោកឡើងទទួលពិធីជ្រមុជទឹក ហើយអង្វររកព្រះនាមព្រះអង្គទៅដើម្បីព្រះអង្គលាងបាបឲ្យ”។ ខ្ញុំវិលមកដល់ក្រុងយេរូសាឡឹមវិញ ហើយនៅពេល

ខ្ញុំកំពុងអធិស្ឋានក្នុងព្រះវិហារ ខ្ញុំលង់ស្មារតី ឃើញព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា “ចូរប្រញាប់ចាកចេញពីក្រុងយេរូសាឡឹមភ្លាមទៅ ដ្បិតអ្នកក្រុងនេះមិនព្រមទទួលសក្ខីភាពដែលអ្នកនិយាយអំពីយើងទេ”។ ខ្ញុំទូលថា “បពិត្រព្រះអម្ចាស់ អ្នកទាំងនោះបានដឹងស្រាប់ហើយថា ទូលបង្គំធ្លាប់ចូលទៅសាលាប្រជុំនានា ចាប់អស់អ្នកដែលជឿព្រះអង្គយកទៅឃុំឃាំង និងវាយដំទៀតផង។ នៅពេលគេសម្លាប់លោកស្ទេផានដែលជាបន្ទាល់របស់ព្រះអង្គ ទូលបង្គំក៏នៅទីនោះ ហើយបានយល់ស្រលបជាមួយពួកគេ ទាំងនៅយាមសម្លៀកបំពាក់របស់ពួកអ្នកដែលប្រហារជីវិតលោកផងដែរ”។ ពេលនោះ ព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា “ទៅចុះ ដ្បិតយើងនឹងចាត់អ្នកឲ្យទៅរកសាសន៍ដទៃដែលនៅឆ្ងាយៗ”»។



ពួកអ្នកដែលជាសាក្សីបានយកសម្លៀកបំពាក់របស់ខ្លួន
ទៅទុកនៅក្បែរជើងយុវជនម្នាក់ឈ្មោះសូល
មុនពេលដែលគេលើកដុំថ្មគប់សម្លាប់លោកស្ទេផាន( កិច្ចការ ៧:៥៨ )។



ព្រះយេស៊ូមានបន្ទូលប្រាប់យុវជនសូលដោយផ្ទាល់ថាព្រះអង្គជាព្រះយេស៊ូដែលគាត់
កំពុងតែបៀតបៀន។ ព្រះអង្គប្រាប់គាត់ឲ្យក្រោកឡើងហើយចូលទៅក្នុងទីក្រុងដាម៉ាស
នៅទីនោះនឹងមានគេប្រាប់គាត់ឲ្យដឹងពីកិច្ចការដែលគាត់ត្រូវធ្វើ( កិច្ចការ ៩:៥-៦ )។



លោកអាណាណាសដាក់ដៃលើសូល ហើយមានប្រសាសន៍ប្រាប់គាត់ថាព្រះអម្ចាស់យេស៊ូ
ដែលសូលបានឃើញនៅតាមផ្លូវគាត់ធ្វើដំណើរមកនោះ ទ្រង់បានចាត់គាត់ឲ្យមកដើម្បីឲ្យសូល
មើលឃើញឡើងវិញ និងឲ្យសូលបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ( កិច្ចការ ៩:១៧ )។



សាវ័កប៉ូលធ្វើបន្ទាល់ប្រាប់ពួកស្ត្រីដែលមកជួបជុំគ្នាអធិស្ឋាន
នៅក្បែរមាត់ទន្លេក្នុងក្រុងភីលីព។ អ្នកស្រីលីឌានិងក្រុមគ្រួសារ
បានទទួលជឿនិងទទួលពិធីជ្រមុជទឹក(កិច្ចការ ១៦:១២-១៥)។



សាវ័កប៉ូលធ្វើបន្ទាល់ប្រាប់ពួកជនជាតិយូដានៅក្រុងបេរា។
ពួកគេនាំគ្នាផ្ទៀងផ្ទាត់សេចក្តីបង្រៀនរបស់គាត់តាមបទគម្ពីរ
ហើយទទួលព្រះបន្ទូលដោយចិត្តស្មោះសរ(កិច្ចការ ១៧:១០-១២)។



សាវ័កប៉ូលធ្វើបន្ទាល់ប្រាប់ទស្សនវិទូខាងអេពីគួរនិងខាងស្តូអ៊ីក
ដែលជួបជុំគ្នានៅសភាក្រុងលើទួលអើរីយ៉ូស( ទួលព្រះអង្គារ )
ក្នុងក្រុងអាថែនប្រទេសក្រិក( កិច្ចការ ១៧:១៦-៣៤ )។



សាវ័កប៉ូលធ្វើបន្ទាល់ប្រាប់ពួកព្រឹទ្ធាចារ្យជនជាតិយូដា
ដែលជាសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់នៅក្រុងយេរូសាឡឹម
នៅចំពោះមុខមេបញ្ជាការរ៉ូម៉ាំង( កិច្ចការ ២១:៣៧-២២:២១ )។



សាវ័កប៉ូលធ្វើបន្ទាល់ប្រាប់ព្រះបាទអគ្រីប៉ា ម្ចាស់ក្សត្រីយ៍បេរេនីស
និងលោកភេស្ទុសដែលជាអភិបាលក្រុងស៊ីសេរា
ពេលលោកផ្តល់ចម្លើយការពារខ្លួន( កិច្ចការ ២៥:១៣-២៦:៣២ )។

## លក្ខណៈសម្គាល់ប្រាំពីរយ៉ាងនៃទីបន្ទាល់ដែលប៉ះពាល់ចិត្ត

### SEVEN CHARACTERISTICS OF A TOUCHING TESTIMONY

ការធ្វើបន្ទាល់ដែលប៉ះពាល់ចិត្តរមែងតែងតែមានលក្ខណៈសម្គាល់ប្រាំពីរយ៉ាងដូចតទៅ៖

- ខ្លី Short – និយាយតាមម៉ោងកំណត់ទើបអ្នកស្តាប់មិនធុញទ្រាន់
- ផ្អែម Sweet – និយាយពីសេចក្តីមេត្តារបស់ព្រះជាម្ចាស់ទើបអ្នកស្តាប់មិនខ្លាចរអា
- ប្រៃ Seasoned – និយាយពីព្រះគុណរបស់ព្រះជាម្ចាស់ទើបអ្នកស្តាប់មិនបាក់ទឹកចិត្ត
- ពិត True – និយាយការពិតឥតមុសាទើបអ្នកស្តាប់មិនសង្ស័យ
- ស្រួល Easy – និយាយស្រួលយល់ទើបអ្នកស្តាប់មិនបាត់ការផ្ចង់ចិត្ត
- ចំៗ Right – និយាយចំចំណុចទើបអ្នកស្តាប់មិនរារែកចិត្ត
- ឮៗ Audible – និយាយល្មមឲ្យគេស្តាប់ឮទើបអ្នកស្តាប់មិនសួរគ្នាឡើងរ៉ល់។

Seven Characteristics of A Touching Testimony, Barnabas Mam, 2010

## ទីបន្ទាល់របស់លោកគ្រូ ម៉ម បាណាបាស
BARNANAS MAM’S TESTIMONY

ខ្ញុំឈ្មោះ ម៉ម សុវណ្ណ ជាកូនរបស់លោក ម៉ម ឡៀប និងអ្នកស្រី អ៊ុន យ៉ិន។ ខ្ញុំកើតនៅភូមិស្ពានថ្ម ឃុំស្ពានថ្ម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ កាលពីក្មេង ខ្ញុំបានរស់នៅជាមួយឪពុកម្តាយរបស់ខ្ញុំនៅភូមិត្រពាំងចក ឃុំព្រៃវែង ស្រុកដង្កោ ខេត្តកណ្តាល។ ខ្ញុំបានទទួលការអប់រំអំពីធម៌ពុទ្ធសាសនា ការព្យាបាលជំងឺបែបបុរាណ និងការសូត្រកំណាព្យពីសំណាក់ឪពុកខ្ញុំ។ ខ្ញុំបានទៅរៀននៅសាលាបឋមសិក្សាពីរគឺសាលាវត្តអង្គមេត្រីនិងសាលាវត្តព្រៃវែង។ ពេលធំឡើង ខ្ញុំបានទៅរៀននៅវិទ្យាល័យជម្ពូវ៉ន ស្រុកដង្កោ ខេត្តកណ្តាល។ ក្រោយមកឪពុកម្តាយខ្ញុំបានបញ្ជូនខ្ញុំទៅរៀនបន្តនៅទីក្រុងភ្នំពេញដោយស្នាក់នៅក្នុងវត្តសារាវ៉ន់តេជោក្រោមការបីបាច់ថែរក្សារបស់ព្រះគ្រូវិរិយសត្ថាសូរ លន់ ជាមេកុដិលេខបី។ ក្រោយមកទៀតខ្ញុំបានចូលរួមក្នុងចលនាយុវជន

កុម្មុយនិស្តកម្ពុជាក្រោមការណែនាំរបស់សកម្មជនកុម្មុយនិស្តម្នាក់ឈ្មោះលោក អាត់ វ៉េត ដែលបានអប់រំខ្ញុំឲ្យយល់ដឹងនិងដើរតាមលទ្ធិម៉ាក្សលេនីន។ នៅខែមេសា ឆ្នាំ១៩៧២ ខ្ញុំបានទៅស៊ើបការណ៍ក្នុងកម្មវិធីផ្សាយដំណឹងល្អមួយនៅសាលសន្និសីទចតុមុខនាក្រុងភ្នំពេញដើម្បីតាមដានឲ្យដឹងពីកលល្បិចរបស់ជនជាតិអាមេរិកនិងបក្សពួករបស់គេជាជនជាតិខ្មែរដែលជាអ្នករៀបចំពិធីផ្សាយដំណឹងល្អនោះឡើង។ ក្រោយពីបានស្តាប់ឮ បណ្ឌិត ស្ទែន មូនីហាំ អធិប្បាយអំពីរឿង«កូនដែលវង្វេង»មក ខ្ញុំក៏បានបើកចិត្តចំហទទួលជឿព្រះយេស៊ូគ្រិស្ត ហើយទទួលព្រះអង្គជាព្រះសង្គ្រោះរបស់ខ្ញុំ។ ខ្ញុំបានទៅថ្វាយបង្គំព្រះជាម្ចាស់នៅព្រះវិហារបេថានីដែលមានចម្ងាយផ្លូវប្រមាណជាដប់ប្រាំនាទីដោយដំណើរជើងពីវត្តអារាមដែលខ្ញុំកំពុងតែស្នាក់នៅនោះ។ ខ្ញុំបានទទួលការអប់រំជំនឿពីសំណាក់ឧបជ្ឈាយ៍គ្រិស្តបរិស័ទបីរូបគឺលោក

សុន សន ជានាយកសមាគមព្រះគម្ពីរ លោក មិញ ធៀនវ៉ែន ជានាយកអង្គការមនុស្សធម៌ និងលោក តាំង ឈាក ជានាយទាហានជើងទឹក។ ខ្ញុំបានចាប់ផ្តើមបម្រើព្រះជាម្ចាស់ជាគ្រូកុមារថ្ងៃអាទិត្យនៅព្រះវិហាររបស់ខ្ញុំ។ នៅសម័យវាលពិឃាដនៃរបបផ្តាច់ការ ប៉ុល ពត ខ្ញុំបានជាប់ឃុំឃាំងនៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង។ បន្ទាប់ពីសម័យវាលពិឃាដគឺនៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំឲ្យដឹកនាំការថ្វាយបង្គំនៅក្នុងក្រុមជំនុំលួចលាក់មួយនា។ បេសកជន អាលីស កុំបាំង បានដាក់ឈ្មោះថ្មីមួយឲ្យខ្ញុំថាបាណាបាសនៅឆ្នាំ១៩៨៣។ ក្រោយមកខ្ញុំបានភៀសខ្លួនទៅស្រុកថៃហើយបម្រើព្រះជាម្ចាស់ក្នុងនាទីជាគ្រូគង្វាលនៅជំរុំសាយធូអស់រយៈពេលប្រាំបីឆ្នាំ។ ខ្ញុំនិងគ្រួសារខ្ញុំបានត្រឡប់មកភ្នំពេញវិញនៅខែមិនា ឆ្នាំ១៩៩៣ ហើយបានបន្តបម្រើព្រះជាម្ចាស់ក្នុងនាទីជាអ្នកផ្សាយដំណឹងល្អនិងគ្រូហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំ។




លោកគ្រូបាណាបាសធ្វើបន្ទាល់ប្រាប់ជនជាតិកួយនៅភូមិស្គន់ក្នុងខេត្តកំពង់ធំ។

៧.ទីបន្ទាល់របស់អ្នក 7. YOUR TESTIMONY

សូមសរសេរទីបន្ទាល់របស់អ្នកឲ្យបានពីរទំព័រដោយបញ្ចូលដំណាក់ការទាំងបួននៃជីវិតអ្នកតាមទីបន្ទាល់គំរូរបស់ប៉ូល។ រួចហើយសូមចែកចាយទីបន្ទាល់នេះជាមួយមិត្តសម្លាញ់របស់អ្នកក្នុងចន្លោះពេលបីទៅប្រាំនាទី។

១.ជីវិតចាស់របស់អ្នកមុនពេលទទួលជឿព្រះគ្រិស្ត
២.កម្លាំងដ៏ខ្លាំងក្លាដែលជំរុញអ្នកឲ្យទទួលជឿព្រះគ្រិស្ត
៣.ព្រឹត្តការណ៍ ពេល និងកន្លែងដែលអ្នកទទួលជឿព្រះគ្រិស្ត
៤.ជីវិតថ្មីរបស់អ្នកក្រោយពេលទទួលជឿព្រះគ្រិស្ត។



សំណួរបញ្ជាក់ការអនុវត្ត

1. តើអ្នកបានធ្វើជាបន្ទាល់(សាក្សី)របស់ព្រះគ្រិស្តឬនៅ?
2. តើអ្នកបានធ្វើបន្ទាល់(ផ្តល់សក្ខីភាព)តាមគំរូរបស់សាវ័កប៉ូលឬទេ?
3. តើជីវិតចាស់របស់អ្នកមានលក្ខណៈបែបណាមុនពេលដែលអ្នកទទួលជឿព្រះគ្រិស្ត?
4. តើមានកម្លាំងខ្លាំងក្លាបែបណាមួយដែលជំរុញអ្នកឲ្យទទួលជឿព្រះគ្រិស្ត?
5. តើអ្នកបានទទួលជឿព្រះគ្រិស្តក្នុងព្រឹត្តិការណ៍អ្វី? នៅពេលណា? នៅកន្លែងណា?
6. តើព្រះគ្រិស្តបានបំផ្លាស់ជីវិតអ្នកត្រង់ចំណុចណាក្រោយពីអ្នកបានទទួលជឿព្រះអង្គ? តើបំណងនៃជីវិតអ្នក ការងារអ្នក និងការរស់នៅអ្នកបានផ្លាស់ប្រែយ៉ាងណាខ្លះ?
7. សូមកែសម្រួលទីបន្ទាល់របស់អ្នកឲ្យបានពីរទំព័រហើយអានឲ្យស្ទាត់ក្នុងពេលប្រាំនាទី។
8. តើអ្នកមានផែនការបែបណាដើម្បីធ្វើបន្ទាល់អំពីព្រះគ្រិស្តឲ្យបានកើតផលច្រើន?
9. សូមទន្ទេញនិងសញ្ជឹងគិតបទគម្ពីរ ម៉ាថាយ ២៤:១៤; វិវរណៈ១២:១១។